MassDEP
Commonwealth of Massachusetts
Executive Office of Energy & Environmental Affairs

Department of Environmental Protection

100 Cambridge Street Suite 900 Boston, MA 02114 • 617-292-5500

Maura T. Healey
អភិបាល

Kimberley Driscoll
អភិបាលរង

Rebecca L. Tepper
លេខាធិការ

Bonnie Heiple
ស្នងការ

# ការជូនដំណឹងអំពីសវនាការសាធារណៈ

ការជូនដំណឹងអំពីសវនាការសាធារណៈនេះ មានផ្តល់ជូនជាភាសាផ្សេងទៀត (អេស្ប៉ាញ -- វៀតណាម -- ចិន -- ក្រេអូលហៃទី -- ព័រទុយហ្គាល់ -- ខ្មែរ) នៅលើគេហទំព័រ MassDEP's តាមរយៈ https://www.mass.gov/service-details/massdep-public-hearings-comment-opportunities

សូមជម្រាបជូនដំណឹងថា ក្រសួងការពារបរិស្ថាន (MassDEP) កំពុងស្នើសុំការធ្វើវិសោធនកម្មលើបទបញ្ញត្តិរបស់ខ្លួនត្រង់ចំណុច 310 CMR 10.00៖ *ការការពារដីសើម* អនុលោមតាមសិទ្ធិអំណាចរបស់ខ្លួនស្របតាមច្បាប់ M.G.L. c. 131, § 40 និងកំពុងស្នើសុំការធ្វើវិសោធនកម្មបទបញ្ញត្តិត្រង់ចំណុច 314 CMR 9.00៖ *401 ការបញ្ជាក់អំពីគុណភាពទឹកសម្រាប់ការបញ្ចេញចោលសារធាតុដែលបានបូមឬចាក់បំពេញ ការបូម និងការបោះចោលស្ថានធាតុដែលបានបូមទៅក្នុងទឹករបស់សហរដ្ឋអាមេរិក នៅក្នុងបរិវេណខមមិនវែល* អនុលោមតាមច្បាប់ M.G.L. c. 21, §§ 26 - 53។ MassDEP កំពុងស្នើសុំការធ្វើវិសោធនកម្មដើម្បីបង្កើតភាពធន់នឹងអាកាសធាតុ និងគោលដៅបរិស្ថាន រួមមានការធ្វើបច្ចុប្បន្នភាពពាក់ព័ន្ធនឹងការប៉ាន់ប្រមាណ តំណក់ទឹកភ្លៀង និងការគ្រប់គ្រងជំនន់ទឹកភ្លៀង និងបទបញ្ញត្តិថ្មីសម្រាប់ដីធ្លីដែលរងនូការជន់លេចតាមមាត់ឆ្នេរ (LSCSF)។

អត្ថបទច្បាប់ដែលបានស្នើសុំ និងការជូនដំណឹងទៅដល់អ្នកត្រួតពិនិត្យ មានផ្តល់ជូនជាមួយនឹងសំណៅឯកសារការជូនដំណឹងអំពីសារនាការសាធារណៈមួយច្បាប់នៅលើគេហទំព័រ MassDEP តាមរយៈ៖ https://www.mass.gov/service-details/massdep-public-hearings-comment-opportunities

MassDEP នឹងរៀបចំសវនាការសាធារណៈតាមប្រព័ន្ធអ៊ីនធឺណិតអនុលោមតាមបទបញ្ញតិ M.G.L. c. 30A នៅកាលបរិច្ឆេទបន្ទាប់ ដើម្បីទទួលបានមតិយោបល់អំពីការផ្លាស់ប្តូរដែលបានស្នើសុំ។ សវនាការនឹងប្រព្រឹត្តទៅតាមប្រព័ន្ធកម្មវិធី Zoom និង**តម្រូវឱ្យមានការចុះឈ្មោះចូលរួមជាមុន។** បន្ទាប់ពីការចុះឈ្មោះ អ្នកនឹងទទួលបានអ៊ីមែលបញ្ជាក់ជាមួយនឹងព័ត៌មានដែលត្រូវការចាំបាច់ដើម្បីចូលរួមក្នុងកិច្ចប្រជុំពីកុំព្យូទ័រ ថេប្លិត ឬទូរស័ព្ទដៃរបស់អ្នក ឬចុចភ្ជាប់ ទំនាក់ទំនងដោយប្រើទូរស័ព្ទរបស់អ្នក។

**ថ្ងៃពុធ ទី 31 ខែមករា ឆ្នាំ 2024 វេលាម៉ោង 1:00 រសៀល**
សូមប្រើប្រាស់តំណភ្ជាប់នេះដើម្បីចុះឈ្មោះចូលរួមជាមុនសម្រាប់សវនាការនេះ៖
https://us06web.zoom.us/meeting/register/tZMvcuirqDwvGdRitIoQan70koiTgaA_Pt9_

**នៅថ្ងៃពុធ ទី 31 ខែមករា ឆ្នាំ 2024 វេលាម៉ោង 6:00 ល្ងាច**
សូមប្រើប្រាស់តំណភ្ជាប់នេះដើម្បីចុះឈ្មោះចូលរួមជាមុនសម្រាប់សវនាការនេះ៖
https://us06web.zoom.us/meeting/register/tZYkduuqpjovHdAzJ539pqn-lQalZ9izohxA

**ថ្ងៃព្រហស្បតិ៍ ទី 1 ខែកុម្ភៈ ឆ្នាំ 2024 វេលាម៉ោង 1:00 រសៀល**
សូមប្រើប្រាស់តំណភ្ជាប់នេះដើម្បីចុះឈ្មោះចូលរួមជាមុនសម្រាប់សវនាការនេះ៖
https://us06web.zoom.us/meeting/register/tZwodOyhpzgsEtR570Cs_gN9GvnyvvNLsfpw

សក្ខីកម្មអាចនឹងផ្តល់ជូនដោយផ្ទាល់មាត់នៅសវនាការសាធារណៈ។ មតិយោបល់ជាលាយលក្ខណ៍អក្សរ នឹងត្រូវបានទទួលយករហូតដល់ម៉ោង 5:00 ល្ងាច **ថ្ងៃទី 1 ខែមីនា ឆ្នាំ 2024។** ក្រសួងលើកទឹកចិត្តឱ្យមានការបញ្ជូនឯកសារតាមអ៊ីមែលទៅកាន់ dep.wetlands@mass.gov ហើយត្រូវតែរួមបញ្ចូល *មតិយោបល់អំពីភាពធន់នៃដីសើម -401* នៅក្នុងជួរកម្មវត្ថុ។ ជំនួសឱ្យការបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក មតិយោបល់ជាក្រដាសអាចនឹងត្រូវបានផ្ញើតាមសំបុត្រប្រៃសណីយ៍ទៅកាន់ Lisa Rhodes តាមរយៈ៖ *Wetlands-401 Resilience Comments*, MassDEP – BWR,100 Cambridge Street, Suite 900, Boston, MA 02114។

សម្រាប់អនុសាសន៍ពិសេសសម្រាប់សវនាការនេះ សូមទូរស័ព្ទទៅកាន់ការិយាល័យពិពិធភាពរបស់ក្រសួង MassDEP តាមរយៈលេខ 617-292-5751។ សេវា TTY# MassRelay តាមរយៈ លេខ 1-800-439-2370។ សេចក្តីជូនដំណឹងនេះ អាចស្វែងរកបានជាទម្រង់ផ្សេងទៀតទៅតាមការស្នើសុំ។ MassDEP ផ្តល់សេវាអ្នកបកប្រែ/ការបកប្រែឯកសារភាសា ជូនដល់បុគ្គលដែលស្ទាត់ជំនាញផ្នែកភាសាអង់គ្លេសនៅមានកម្រិត ដោយឥតគិតថ្លៃ។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះ សេវាបកប្រែអាចនឹងទទួលបានតាមតំណភ្ជាប់ខាងក្រោម៖ https://www.mass.gov/info-details/massdep-language-translation-assistance.

តាមសេចក្តីបង្គាប់របស់ក្រសួងការពារបរិស្ថាន
Bonnie Heiple ស្នងការ